**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១២៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបំបែកអគ្គនាយកដ្ឋានយុវជន ចេញពីអគ្គនាយកដ្ឋានយុវជន និងកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ខែ ឆ្នាំ២០០

## សម្រេច

**មាត្រា១.**

ត្រូវបាន បំបែកអគ្គនាយកដ្ឋានយុវជន ចេញពីអគ្គនាយកដ្ឋានយុវជន និងកីឡា ស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អគ្គនាយកដ្ឋានយុវជន ទទួលបន្ទុកទំនាក់ទំនង សម្របសម្រួល និងគ្រប់គ្រងកិច្ចការយុវជន និងកុមារនៅក្នុងក្របខ័ណ្ឌក្រសួង និងសង្គមជាតិ ដែលមាននាយកដ្ឋានចំណុះចំនួនពីរ (០២) មានភារកិច្ចដូចមានចែងក្នុងអនុក្រឹតនេះ ។

អគ្គនាយកដ្ឋានយុវជន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយ ការតាមការចាំបាច់ ។

**មាត្រា៣.-**

នាយកដ្ឋានយុវជនមានភារកិច្ចដូចតទៅ ៖

- កសាងគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានដើម្បីអភិវឌ្ឍការងារយុវជន និងកុមារ
- សហការជាមួយអង្គភាព និងដៃគូអភិវឌ្ឍន៍លើការងារយុវជន និងកុមារ
- បណ្តុះបណ្តាលនូវបញ្ញា ស្មារតី និងចំផុសចិត្តគំនិតយុវជន និងកុមារ ឱ្យមាន សីលធម៌រស់នៅថ្លៃថ្នូរ គិតគូរពីបញ្ហាបុគ្គលខ្លួនឯង គ្រួសារ សង្គមប្រទេសជាតិ
- លើកកម្ពស់ចលនាប្រឡងប្រណាំង ពលល្អ កូនល្អ សិស្សល្អ មិត្តល្អ របស់កុមារ និងយុវជន ។

នាយកដ្ឋានយុវជន ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា៤.-**

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលមានភារកិច្ចដូចតទៅ៖

- ណែនាំការបង្កើត និងការរៀបចំដំណើរការអភិវឌ្ឍ មជ្ឈមណ្ឌលយុវជន ខេត្ត ក្រុង
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីណែនាំ និងអប់រំយុវជនក្រៅសាលាឱ្យទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ជីវភាពរស់នៅ និងចំណិនការងាររបស់ខ្លួន
- លើកកម្ពស់ការស្ម័គ្រចិត្តរបស់យុវជន ក្នុងការចុះជួយការងារនៅតាមមូលដ្ឋាននានា
- សិក្សាស្រាវជ្រាវ និងរៀបចំផែនការសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិខេត្ត ក្រុង ។

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ